THE COMMONWEALTH OF MASSACHUSETTS
OFFICE OF THE ATTORNEY GENERAL
ONE ASHBURTON PLACE
BOSTON, MASSACHUSETTS 02108

MAURA HEALEY
ATTORNEY GENERAL

(617) 727-2200
(617) 727-4765 TTY
www.mass.gov/ago

**សម្រាប់ការបញ្ចេញទំនាក់ទំនង**
**ថ្ងៃទី 27 ខែមករា ឆ្នាំ 2022,**

**ប្រព័ន្ធព័ត៌មាន ៖**
**Roxana Martinez-Gracias**
**(617) 727-2543**

## ការិយាល័យរបស់ AG HEALEY បង្កើនការយល់ដឹងអំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ដោយឆបោកក្លែងបន្លំ

*បាយការណ៍សហគមន៍កើនឡើងនៅក្នុង "ការក្លែងបន្លំ Notario"; ការិយាល័យរបស់ AG អប់រំពលរដ្ឋដែលត្រូវការជំនួយផ្នែកច្បាប់អំពីរបៀបការពារប្រឆាំងនឹងការបោកប្រាស់*

**ទីក្រុង BOSTON** – ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងបន្តរបស់ការិយាល័យរបស់នាងក្នុងការតស៊ូមតិសម្រាប់សហគមន៍អន្តោប្រវេសន៍របស់រដ្ឋ អគ្គមេធាវី Maura Healey បានប្រកាសថាការិយាល័យរបស់អ្នកស្រីបានបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីជូនដំណឹង និងការពារអ្នកស្រុកពីការក្លែងបន្លំការអនុវត្តច្បាប់អន្តោប្រវេសន៍ ។

យុទ្ធនាការអប់រំពហុភាសា ជាដំបូងបានតម្លើងក្នុងឆ្នាំ 2018 ដោយ នាយកដ្ឋានសហគមន៍របស់ AG, ផ្តោតលើការផ្តល់ព័ត៌មានសហគមន៍ជនអន្តោប្រវេសន៍អំពីការអនុវត្តដែលគួរឲ្យខ្លាចទាំងនេះ និងឧបករណ៍ និងគន្លឹះដែលចាំបាច់ដើម្បីជួយការពារខ្លួន ។ ការិយាល័យ AG បានចាប់តាំងពីពេលនោះមក ការិយាល័យ បានបើកដំណើរការឡើងវិញនូវសម្ភារៈអប់រំ និងការផ្សព្វផ្សាយរបស់ខ្លួន បន្ទាប់ពីបានឮពីសហគមន៍អំពីមេធាវីដែលមិនសមហេតុផលដែលទាញយកផលប្រយោជន៍ពីកូនក្តីរបស់ពួកគេ និងការបោកប្រាស់យ៉ាងទូលំទូលាយដែលគេស្គាល់ថាជា “ការក្លែងបន្លំណូតារីយ៉ូ” ឬជាការប្រព្រឹត្តលើច្បាប់អន្តោប្រវេសន៍ ដោយគ្មានច្បាប់ ។

អ្នកស្រី AG Healey បាននិយាយថា "ជាអកុសល យើងបន្តឃើញការបោកប្រាស់ដែលផ្តោតលើសហគមន៍ជនអន្តោប្រវេសន៍ និងឈ្លានពានចាប់អ្នកដែលត្រូវការជំនួយផ្នែកច្បាប់ដោយយកប្រាក់របស់ពួកគេ ហើយទុកឱ្យពួកគេគ្មានជំនួយតិចតួច” ។ “ការិយាល័យរបស់ខ្ញុំបម្រើជាធនធានដើម្បីការពារប្រជាពលរដ្ឋរបស់យើង ពីការចាញ់បោក ហើយនឹងបន្តចាត់វិធានការដើម្បីបិទការអនុវត្តខុសច្បាប់ទាំងនេះ”។

អ្នកបោកប្រាស់បោកបញ្ឆោតជនរងគ្រោះ - ជាញឹកញាប់តាមរយៈការផ្សាយពាណិជ្ជកម្ម - ជាមួយនឹងការសន្យាដែលទំនងទៅដូចជាល្អពេកដើម្បីជាការពិត រួមទាំងការជួយ ដើម្បីទទួលបានកាតបៃតង ទិដ្ឋាការ ឬការធ្វើស្របច្បាប់ជាថ្នូរនឹងប្រាក់ ។ ក្នុងករណីខ្លះ ជនរងគ្រោះអាចត្រូវបានទាមទារប្រាក់រហូតដល់រាប់ម៉ឺនដុល្លារសម្រាប់សេវាដែលមានគ្មានតម្លៃពីបុគ្គលដែលមិនមានអាជ្ញាប័ណ្ណមេធាវីអន្តោប្រវេសន៍ ។

ជាផ្នែកនៃកិច្ចខិតខំប្រឹងប្រែងយល់ដឹង ដែលកំពុងបន្តទាំងនេះការិយាល័យរបស់ AG នឹងតភ្ជាប់ជាមួយសហគមន៍ជនអន្តោប្រវេសន៍ តាមវិធីជាច្រើនរួមទាំងការប្រកាសអំពីសេវាសាធារណៈពហុភាសាឬ PSA ការបង្ហោះប្រព័ន្ធផ្សព្វផ្សាយសង្គម គេហទំព័រគោលដៅ មួយអំពីរបៀបជៀសវាងការបោកប្រាស់អន្តោប្រវេសន៍ ដែលមានជាភាសាអង់គ្លេស ព័រទុយហ្គាល់ និង អេស្ប៉ាញ និងផ្ទាំងរូបភាព (មានជាភាសាអង់គ្លេស ព័រទុយហ្គាល់ អេស្ប៉ាញ រុស្ស៊ី ចិន ខ្មែរ និងហៃទី គ្រេអូល ជាមួយនឹងគន្លឹះមានប្រយោជន៍ ។ ការិយាល័យរបស់ AG ក៏នឹងធ្វើការជាមួយដៃគូសហគមន៍ និងសមាជិកសភាក្នុងមូលដ្ឋាន ដើម្បីជួយយកព័ត៌មាននេះចេញទៅកាន់អ្នកស្រុក ដែលនឹងទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីវា ។ ក្រសួង ទំនាក់ទំនងសហគមន៍របស់ AG ក៏នឹងរៀបចំសិក្ខាសាលាតាមគេហទំព័រ និងការបណ្ដុះបណ្ដាលដោយផ្ទាល់ អំពីរបៀបកំណត់អត្តសញ្ញាណការឆបោក ខាងអន្តោប្រវេសន៍ ហើយនិងរបៀបដើម្បីការពារខ្លួនពីពួកគេ ។

ពលរដ្ឋត្រូវបានលើកទឹកចិត្តឲ្យបំពេញដំណាក់ការ ខាងក្រោមដើម្បីជៀសវាងនូវការឆបោកច្បាប់អន្តោប្រវេសន៍ ៖

- បញ្ជាក់ថាមេធាវីរបស់អ្នកមានអាជ្ញាបនប័ត្រ ។ មានតែ មេធាវីមានអាជ្ញាបនប័ត្រ – ឬនរណាម្នាក់ បានទទួលការអនុញ្ញាតដោយរដ្ឋាភិបាលសហព័ន្ធ អាច ៖
  - o តំណាងឲ្យអ្នកក្នុងតុលាការឬមុននឹងចៅក្រមរដ្ឋបាលម្នាក់ ។
  - o ផ្ដល់ឱវាទ ដល់អ្នកថ្វីបើអ្នកគួរតែដាក់ពាក្យសុំអត្ថប្រយោជន៍ ឬការការពារឬអត់ ។
  - o ពន្យល់ប្រាប់ជម្រើសខាងច្បាប់របស់អ្នកហើយផ្ដល់ដល់អ្នកនូវឱវាទខាងច្បាប់ ។
- មិនដែលបង់ប្រាក់សម្រាប់ទម្រង់អន្តោប្រវេសន៍ឡើយ ។ វាមានសម្រាប់អ្នកដោយមិនចាំបាច់អស់លុយ ។
- កុំចាកចេញពីការិយាល័យមេធាវីរបស់អ្នកដោយគ្មានវិក្កយបត្រសម្រាប់ការទូទាត់ទាំងអស់ឡើយ ។
- កុំចុះហត្ថលេខាលើទម្រង់ ទទេឲ្យសោះ ។
- ធ្វើយ៉ាងណាអ្នកយល់អំពីទម្រង់ណាមួយដែលមេធាវីរបស់អ្នកកំពុងធ្វើជំនួសអ្នក ។
- រក្សាឯកសារផ្ទាល់ខ្លួនដើមរបស់អ្នក ។
- រក្សាទុកការថតចម្លងទាំងអស់ ។

ការិយាល័យរបស់ G ពីមុនមកបានបញ្ចេញសកម្មភាព ប្រឆាំងនឹងបុគ្គលសម្រាប់ការកេងប្រវ័ញ្ចពលរដ្ឋដែលស្វែងរកសេវាអន្តោប្រវេសន៍ ។  ក្នុងឆ្នាំ 2018,ការិយាល័យរបស់ AG បានប្ដឹងលោក George C. Maroun Jr. ពីបទប្រព្រឹត្តការឆបោកសិទ្ធិជ្រកកោន ដែលបានធ្វើ ការសន្យាក្លែងក្លាយ និងការជានាកាតបែគងដល់អតិថិជន ។ Maroun ក៏ត្រូវបានចោទប្រកាន់ថាបានដាក់ពាក្យសុំសិទ្ធិជ្រកកោនដោយគ្មានការយល់ដឹង ឬការយល់ព្រមពីអតិថិជនរបស់គាត់ ដែលខ្លះមានការពិតដែលបានបង្កើតឡើង និងការបង្ហាញមិនពិត ហើយអាចបណ្ដាលឱ្យអតិថិជនត្រូវបានដាក់ក្នុងដំណើរការដកចេញ ។ ការិយាល័យរបស់ AG បានទៅការកាត់ទោសនៅខែតុលាឆ្នាំ 2021 ប្រឆាំងនឹង Maroun នៅក្នុងតុលាការជាន់ខ្ពស់ Middlesex ហើយបច្ចុប្បន្នកំពុងរង់ចាំការសម្រេចរបស់តុលាការ ។

ក្នុងឆ្នាំ 2016, Gerson Barahona,បុរស Waltham ម្នាក់ត្រូវបានបញ្ជាឲ្យបង់ប្រាក់ជាង $155,760 ជាសំណងដល់ជនរងគ្រោះ ពិន័យរដ្ឋប្បវេណីនិងថ្លៃមេធាវី បន្ទាប់ពីបានធ្វើជាមេធាវីអន្តោប្រវេសន៍ និងគិតប្រាក់រាប់រយ ឬរាប់ពាន់ដុល្លារដោយខុសច្បាប់សម្រាប់ដំបូន្មាន និងសេវាផ្នែកច្បាប់ ។ ការិយាល័យរបស់ AG បានស្វែងរកនិងទទួលបានដីកាបឋមមួយក្នុង  ខែធ្នូឆ្នាំ 2014 តម្រូវឲ្យ Barahona ឈប់ផ្ដល់សេវាណាមួយទាក់ទងនឹងរឿងរ៉ាវអន្តោប្រវេសន៍ ។

ដើម្បីរាយការណ៍អំពីការឆបោកខាងអន្តោប្រវេសន៍ សូមទូរស័ព្ទទៅនាយកដ្ឋាន សិទ្ធិស៊ីវិលរបស់ AG លេខ (617) 963-2917 ។ ដើម្បីរៀនថែមទៀត សូមចូលទៅ www.mass.gov/immigrationscams

ដើម្បីទស្សនាការផ្សព្វផ្សាយព័ត៌មាននេះក្នុងភាសា អេស្ប៉ាញ សូមចុច ដើម្បីទស្សនាការផ្សព្វផ្សាយព័ត៌មាននេះក្នុងភាសា ពុយទូគុយ, សូមចុច ។

####